## ការបញ្ជា (ordering)

ការបញ្ជាគឺជាទម្រង់ទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល។ ធាតុផ្សំអត្តនោម័ត ទាមទារយ៉ាងហោចណាស់ អ្នកចេញបញ្ជា បានដឹងនូវហានិភ័យ ថាបទឧក្រិដ្ឋ នឹងត្រូវបានប្រព្រឹត្តនៅពេលអនុវត្តតាមបទបញ្ជារបស់ខ្លួន។ យុត្តិសាស្ត្ររបស់តុលាការខ្លះ ទាមទារនូវភាពដែលអាចនឹងកើតមាន (substantial likelihood) ថាបទល្មើសនឹងត្រូវបានប្រព្រឹត្ត។ ការបញ្ជា ជាមួយនឹងការដឹងដូចនេះ មានន័យថា អ្នកបញ្ជាបានទទួលយកនូវបទឧក្រិដ្ឋ។ បទបញ្ជា មិនចាំបាច់ជាលាយលក្ខណ៍អក្សរទេ ពីព្រោះគេអាចទាញការសន្និដ្ឋាន តាមភស្តុតាងប្រយោល (circumstantial evidence)។

ឋានៈនៃអ្នកចេញបញ្ជា ត្រូវបានតម្រូវឲ្យមាន ក៏ប៉ុន្តែមិនទាមទារនូវលក្ខខណ្ឌនៃការគ្រប់គ្រងមានប្រសិទ្ធភាព (effective control) លើអ្នកទទួលបញ្ជា (អ្នកក្រោមបង្គាប់)ទេ។ វាជាការគ្រប់គ្រាន់ហើយ ក្នុងករណីដែលជនល្មើស មានអំណាចលើចារីនៃបទល្មើស ហើយការបញ្ជា បង្កជាផលវិបាកធន់ល្មម និងផ្ទាល់លើការប្រព្រឹត្តអំពើខុសច្បាប់ (*Kamuhanda*, ICTR-99-54A-A, 2005, S. 75)។

រដ្ឋអាជ្ញា ត្រូវបង្ហាញថា ជនល្មើសបានចេញបញ្ជា ដោយបញ្ជាក់នូវសំណួរមួយចំនួន៖ តើជនល្មើសអាចចេញបញ្ជាបានឬទេ? អ្វីទៅជាបទបញ្ជា ព្រមទាំងចំណងទាក់ទង រវាងបទបញ្ជា និងបទឧក្រិដ្ឋ?។ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 446-448)។